**ការផ្សាយសារព័ត៌មានបន្ទាន់:**

ការអំពាវនាវពី សុបពើ សង្គហ: សំរាប់ជនរងគ្រោះពីការរញ្ជួញដីនៅ យូស៊ី

តាងនាមអោយសម្ព័ន្ធភាពសាសនាមិនប្រកាន់និកាយនៃក្រុមសង្ឃពុទ្ធសាសនា និងពុទ្ធសាសនិកជន បួងសួងសំរាប់សន្តិភាពក្នុងទីបេ ប្រចាំប្រទេសជប៉ុន សូមបញ្ជូនបន្តការផ្សាយសារព័ត៌មាន និង បដ្ឋនាលិខិតមានសេចក្តីដូចខាងក្រោម:

សូមអញ្ជើញបន្ថែមឈ្មោះរបស់អ្នក ឈ្មោះស្ថាប័ន ។ល។ នៅក្នុងបដ្ឋនាលិខិត ដោយធ្វើការទំនាក់ទំនង eliwakamatsu@googlemail.com

***ចំណាំ:*** សូមវាយបន្ថែម Yusho Earthquake Appeal by Super Sangha នៅក្នុងប្រធានបទ (Subject)។

សេចក្តីថ្លែងការណ៍នឹងមានផ្សាយក្នុងគេហទំព័រ http://www.supersangha.jp/

ពួកគេនឹងរៀបចំធ្វើសន្និសិទការសែតនៅក្លឹបអ្នកកាសែតបរទេសនៅក្រុងតូក្យូ។ ប្រសិនបើលោកអ្នកជាសមាជិក នៃប្រព័ន្ធផ្សព្វផ្សាយ សូមទំនាក់ទំនង:

**Rev.Wakaomi Takashi**; Chief Pries, Zenkoji-Tokugyoubou,
Temple (Japanese)
lauramari1207@docomo.ne.jp/tokugyoubou@gmail.com

Eli Wakamatsu (English/ Japanese)
+44 7711 746 172
eliwakamatsu@googlemail.com

# សេចក្តីថ្លែងការណ៍អំពីគ្រោះមហន្តរាយរញ្ជួយដីនៅយូស៊ី របស់ សុបពើ សង្គហៈ (សម្ព័ន្ធភាពសាសនានិកាយចំរុះ នៃក្រុមសង្ឃពុទ្ធសាសនា និងពុទ្ធសាសនិកជន តាំងទ្រនីបេ)

យើងខ្ញុំជាសមាជិកបុព្វជិត និងសហគមន៍ពុទ្ធសាសនាដែលមកពីគ្រប់គណៈ និងគ្រប់និកាយ សូមចូលរួមទុក្ខព្រួយដ៏ជ្រាលជ្រៅបំផុត និងសូមធ្វើការបួងសួងដល់អ្នកស្លាប់ដែលជាជនរងគ្រោះពីការរញ្ជួយដីថ្មីៗនេះ នៅក្នុងខេត្ត យូស៊ី ជីងហាយ ប្រទេសចិន។ យើងខ្ញុំក៏សូមធ្វើការបួងសួងដល់ជនទាំងឡាយដែលបានទទួលរងរបួស និងកំពុងតែប្រយុទ្ធតស៊ូដើម្បីរស់ក្រោមព្រឹត្តការណ៍ដ៏គួរអោយភ័យខ្លាចនេះ ដោយសូមអោយកិច្ចប្រឹងប្រែងសង្គ្រោះនៅតែស្វែងរកឃើញជនទាំងឡាយ ដែលកំពុងជាប់ក្រោមកំទេចថ្មបាក់បែករហូតដល់ដំណាក់កាលណានៅតែមានសញ្ញាថាមានអ្នកត្រូវសង្គ្រោះ។

យើងខ្ញុំបានអានរួចហើយនូវលិខិតរបស់ប្រជាជនទីបេរស់នៅក្នុងតំបន់រញ្ជួយដី ផ្ញើជូនលោកប្រធានាធិបតី ហ៊ូ និងលោកនាយករដ្ឋមន្ត្រី វ៉ែន ដោយធ្វើការស្នើសុំអោយមានការអញ្ជើញមកសួរសុខទុក្ខ និងសេចក្តី ថ្លែងការណ៍ចូលរួមទុក្ខ របស់ព្រះតេជគុណ Dalai Lama ដែលមានបំណងយ៉ាងជ្រាលជ្រៅមកសួរសុខទុក្ខជនរងគ្រោះ នៅហ្សូ។

យើងខ្ញុំសូមធ្វើការជំរុញយ៉ាងខ្លាំងក្លាដល់បណ្តារអ្នកដឹកនាំទាំងឡាយរបស់បក្សកុំមុយនីសចិន រដ្ឋាភិបាលកណ្តាល ធ្វើការឆ្លើយតបដល់បំណងប្រាថ្នាជាមូលដ្ឋានសីលធម៌ដែលមានលក្ខណៈស្របច្បាប់ និងសាមញ្ញ ដោយយោងលើលទ្ធិពុទ្ធសាសនា "**សេចក្តីមេត្តា**" ដែលឆ្លុះបញ្ចាំងពីសារមនុស្សធម៌ ដែលលាតសន្ធឹងលើសពីភាពខុសគ្នានៃអធិបតេយ្យជាតិ សញ្ជាតិ ជាតិពន្ធ ឬ យ៉េនឌ័រ។

ការបាន ឬមិនបានជួបគ្នារបស់ជនរងគ្រោះ និងព្រះតេជគុណ Dalai Lama គឺអាស្រ័យទាំងស្រុងទៅលើសេចក្តីសំរេចរបស់រដ្ឋាភិបាលកណ្តាលនៃបក្សកុំមុយនីស្តចិន និងកិច្ចប្រឹងប្រែងរបស់ប្រជាជនចិននៅក្នុង និងក្រៅប្រទេស ដែលពួកគេមានប្រវត្តិសាស្ត្រពីបុព្វកាលប្រកបដោយគតិបណ្ឌិត និងកិត្តិយស សាយភាយគ្រប់ទិសទីក្នុងពិភពលោក។

យើងមានជំនឿដោយស្មោះត្រង់ថា នេះគឺអាចជាយុគថ្មីមួយចំពោះការបំពេញប្រវត្តិសាស្ត្រទំនើបរបស់យើង ដែលប្រកបដោយកិច្ចប្រឹងប្រែងគ្រប់រូបភាពដើម្បីលុបបំបាត់ការខុសគ្នារវាង អំណាច និងការបង្ខំជាមួយនឹង សេចក្តីសំរេចចិត្តរបស់ប្រជាជនចិនក្នុងការគោរព និងសំដែងនូវមនុស្សធម៌ពិតៗ ដោយអនុញ្ញាតិអោយមានការជួបគ្នានេះកើតឡើង ហើយការជួបគ្នានេះនឹងបង្ហាញអោយឃើញពីការប្រតិបត្តិដ៏សំខាន់ដើម្បីសន្តិភាព ដែលសមស្របនឹងគំនិតយើងជាច្រើននាក់។

ដូច្នេះយើងសូមអំពាវនាវមិនត្រឹមតែដល់រដ្ឋាភិបាល ស្ថានទូត និងស្ថានកុងសុលរបស់យើងប្រចាំប្រទេសចិនប៉ុណ្ណោះទេ គឺយើងសូមធ្វើការអំពាវនាវដល់បណ្តារមេដឹកនាំបក្សគុំមុយនីស្តចិន ប្រជាជាតិចិនដីគោក នៅ Diasporas និងប្រជាជនទូទាំងពិភពលោក សូមរួបរួមជាមួយយើងខ្ញុំគាំទ្រការអំពាវនាវ ដើម្បីអោយមានការបង្រួបបង្រួមពុទ្ធសាសនិកជន ក្នុងទីបេ និង Dalailama ។

ក្នុងរយះពេលប៉ុន្មានឆ្នាំថ្មីៗនេះពុទ្ធសាសនិកជននៅក្នុងទីបេ និងភូមាបានធ្វើបាតុកម្មដោយមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន ដូចនេះយើងត្រូវតែគាំទ្ររាល់ការបរិយាយនូវរាល់អំពើខុសនឹងអភិសមាចារ និងគន្លងសីលធម៌ ដែលទាំងនេះយើងអាចមើលឃើញថាជាករណីយកិច្ចរបស់សាសនា និងពុទ្ធសាសនិកជន។

យើងសូមធ្វើការពឹងពរដល់ពុទ្ធសាសនិកជនក្នុងប្រទេសជប៉ុន អាស៊ី ពិភពលោក ប្រជាជនទីបេ និងរាល់មេដឹកនាំសាសនាទាំងឡាយ ចូលរួមជាមួយយើងខ្ញុំគាំទ្រការអំពាវនាវដ៏ស្មោះត្រង់របស់ជនរងគ្រោះនៅយូស៊ី និងព្រះតេជគុណ Dalai lama ដើម្បីអនុញ្ញាត្តិព្រះតេជគុណបានធ្វើទស្សនកិច្ចសួរសុខទុក្ខ ជនរងគ្រោះទាំងនោះ។

**ប្រធាន សុបពើ សន្តហះ**
**សម្ព័ន្ធភាពសាសនាមិនប្រកាន់និកាយនៃក្រុមសង្ឃពុទ្ធសាសនា និងពុទ្ធសាសនិកជន គាំទ្រទីបេ**

សូមអានសំបុត្ររបស់ប្រជាជនទីបេនៅតំបន់រញ្ជួយដីផ្ញើរទៅកាន់លោកប្រធានាធិបតី ហ៊ូ និងលោកអនុប្រធានាធិបតិ វ៉េន ក្នុងការស្នើសុំអោយមានទស្សនកិច្ចសួរសុខទុក្ខរបស់ព្រះតេជគុណ Dalai lama ចេញផ្សាយថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១០ និងសេចក្តីរាយការណ៍របស់ព្រះតេជគុណ Dalai lama នៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១០។

បណ្តនាលិខិតត្រូវបានចុះហត្ថលេខីដោយ:

……………………

……………………

……………………

ប្រសិនបើលោកអ្នកគាំទ្រចំពោះសេចក្តីថ្លែងការណ៍របស់យើងខ្ញុំខាងលើ សូមអញ្ជើញចុះឈ្មោះរបស់លោកអ្នក ឈ្មោះក្រុម ឬ និកាយ ព្រមទាំងប្រទេសកំណើត ឬ សញ្ជាតិរបស់លោកអ្នក។

អត្ថបទដើមសរសេរជាភាសាជប៉ុន

លោកប្រធានាធិបតី ហ៊ូ និងលោកនាយករដ្ឋមន្ត្រី វ៉េន ជាទីគោរព

យើងខ្ញុំសូមគោរពជូនពរលោកទាំងពីរមានសុខភាពល្អ។ យើងខ្ញុំជាជនរងគ្រោះក្នុងវិបត្តិភ័យនេះ មានសេចក្តីត្រេកអរ និងអរគុណ ចំពោះកិច្ចប្រឹងប្រែងបន្ទាន់របស់រដ្ឋាភិបាល ដែលធ្វើអោយមានការធូរស្បើយ តាមរយៈកំលាំងយោធា និងរាល់កិច្ចគាំទ្រខុសៗគ្នាពីគ្រប់មជ្ឈដ្ឋានសង្គម ចាប់តាំងពីម៉ោងដំបូងនៃគ្រោះមហន្តរាយធម្មជាតិនេះ។

ប៉ុន្តែយើងខ្ញុំទាំងអស់គ្នាជាសហគមន៍សាសនាមួយដ៏ជ្រាលជ្រៅ ដែលមានជំនឿខ្លាំងក្លាលើការប្រៀនប្រដៅរបស់ព្រះពុទ្ធ។ យើងមានជំនឿលើព្រះតេជគុណ Dalai Lama ជាច្រើនជំនាន់មកហើយ។ ថ្ងៃនេះ យើងទទួលរងនូវភាពតានតឹងយ៉ាងខ្លាំងទាំងផ្លូវកាយ និងផ្លូវចិត្ត ហើយយើងខ្ញុំពិតជាត្រូវការព្រះអង្គនិមន្តមកទស្សនកិច្ចតំបន់ទទួលរងការរញ្ជួយដី ដើម្បីព្រះអង្គបានសូត្រធម៌ឧទ្ទិសដល់វិញ្ញាណក្ខន្ធដែលស្លាប់ និងព្រមទាំងផ្តល់នូវការលួងលោមដល់បេះដូងបែកប្រេះស្រាំរបស់យើងខ្ញុំអោយបានធូរស្បើយ។ ថ្ងៃនេះ យើងខ្ញុំសូមស្នើសុំដល់លោកប្រធានាធិបតី ហ៊ូ និងលោកនាយករដ្ឋមន្ត្រី វ៉េន មានចិត្តមេត្តា និងមេត្តាបំពេញបំណងប្រាថ្នារបស់ជនរងគ្រោះ រញ្ជួយដីនេះផង។ យើងខ្ញុំជាជនរងគ្រោះដែលមានចំនួនច្រើនជាង ១០.០០០នាក់ សូមអង្វរករលោកដោយចិត្តស្មោះអស់ពីបេះដូង សូមលោកបំភ្លេចចោលពីភាពខុសគ្នានៃគោលនយោបាយរដ្ឋាភិបាលរបស់លោកចំពោះ ព្រះតេជគុណ Dalai Lama ហើយសូមលោកធ្វើការពិចារណាលើសំណើរបស់យើងខ្ញុំដោយក្តីអនុគ្រោះ។

ជាមួយនឹងការអញ្ជើញរបស់ព្រះតេជគុណ Dalai Lama យើងខ្ញុំមិនមានបំណងអ្វីផ្សេងទៀតទេ ក្រៅពីបំពេញសេចក្តីប្រាថ្នាតាមបែបសាសនា នៃការឧទ្ទិសបួងសួងដល់វិញ្ញានក្ខន្ធដែលស្លាប់ និងជនរស់រានមានជីវិតក្នុងគ្រោះមហន្តរាយនេះ។

ក្នុងវេលាម៉ោងនៃទុក្ខព្រួយនេះ មានតែទស្សនកិច្ចរបស់ព្រះតេជគុណដើម្បីឧទ្ទិសបួងសួង និងចូលរួមរំលែកទុក្ខព្រួយជាបុគ្គលដោយផ្ទាល់ទេ ដែលអាចធ្វើអោយដំបៅបេះដូងយើងខ្ញុំជាសះស្បើយបាន។
គ្មានវិធីណាដែលល្អ ជាងនេះទេ។

# សេចក្តីថ្លែងការណ៍របស់ព្រះតេជគុណ Dalai Lama

ព្រះតេជគុណ ដាឡាយ ឡាម៉ា មានបំណងខ្លាំងណាស់ក្នុងការនិមន្តធ្វើទស្សនកិច្ចទៅតំបន់ដែលទទួលរងគ្រោះរញ្ជួយដី ដូចដែលខ្ញុំបានធ្វើកំណត់សំគាល់ខ្លីភ្លាមៗ បន្ទាប់ពីខ្ញុំបានឮព័ត៌មាន។ ខ្ញុំមានសេចក្តីក្រៀមក្រំយ៉ាងពន់ពេក ពីផលវិបាកនៃគ្រោះមហន្តរាយរញ្ជួយដីនៅ យូស៊ី តំបន់ស្វយ័តទីបេ (ទីបេៈ ឃ្យីចូដូ) ខេត្តជីងហាយ ដែលបានទទួលរងនូវសោនាដកម្មបាត់បង់អាយុជីវិតជាច្រើន បន្សល់ទុកជនរងគ្រោះច្រើននាក់ និងការបាត់បង់ទ្រព្យសម្បត្តិជាច្រើន។ បច្ចុប្បន្ននេះខ្ញុំមិនអាចចូលរួមសំរាលទុក្ខដល់ជនរងគ្រោះដោយផ្ទាល់នោះទេ ដោយសារគំលាតរូបរាងកាយរវាងយើង ប៉ុន្តែខ្ញុំសូមអោយពួកគេដឹងថាខ្ញុំកំពុងធ្វើការបួងសួង ឧទ្ទិសដល់ពួកគេ។

ខ្ញុំសូមសរសើរដល់សហគមន៍បុព្វជិក ប្រជាជនក្មេងៗ និងបុគ្គលជាច្រើនទៀតនៅតំបន់ក្បែរៗនោះ ចំពោះការគាំទ្រជាអ្នករស់នៅក្បែរខាង ព្រមទាំងជំនួយទៅកាន់ក្រុមគ្រួសារទាំងឡាយដែលបានបាត់បង់គ្រប់បែបយ៉ាង។ សូមអោយសេចក្តីមេត្តាគំរូនេះ បន្តដុះដាលជារៀងរហូត។ ការងារស្ម័គ្រចិត្តបំរើអ្នកដទៃបែបនេះ គឺជា ការអនុវត្តបូជាសេចក្តីប្រាថ្នា របស់ព្រះពោធិ៍សត្តពិតៗ។

ខ្ញុំក៏សូមសរសើរដល់អាជ្ញាធរចិនទាំងឡាយ ដែលមកសួរសុខទុក្ខតំបន់ទទួលរងគ្រោះ ជាពិសេសគឺលោកប្រធានាធិបតី វ៉ែន ជីប៉ាវ ដែលមិនត្រឹមតែខ្លួនលោកផ្ទាល់បានចូលរួមសំរាលទុក្ខលំបាករបស់សហគមន៍ទទួលរងគ្រោះប៉ុណ្ណោះទេ គឺថែមទាំងចុះពិនិត្យមើលកិច្ចការសង្គ្រោះបន្ថែមទៀតផង។ ខ្ញុំក៏សូមអបអរផងដែរ ចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលមានសេរីភាពក្នុងរាយការណ៍អំពីសោនាដកម្ម និងផលវិបាកក្រោយសោនាដកម្មនេះ។

ក្នុងឆ្នាំ២០០៨ នៅពេលដែលមានការរញ្ជួយដីប្រហាក់ប្រហែលនេះកើតឡើងនៅស៊ីជួន មេដឹកនាំរដ្ឋាភិបាលកណ្តាល និងមូលដ្ឋានចិន ព្រមទាំងអាជ្ញាធរផ្តល់ជំនួយ បានខ្នះខ្នែងយ៉ាងខ្លាំងក្នុងការជួយសង្គ្រោះ ការផ្តល់សេរីភាពដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក៏ដូចគ្នានឹងការបើកផ្លូវអោយភ្នាក់ងារជួយសង្គ្រោះបរទេសចូលផ្តល់ជំនួយតាមតំរូវការ។ ខ្ញុំសូមសរសើរចំពោះការផ្លាស់ប្តូរជាវិជ្ជមាននេះ ហើយខ្ញុំសូមអំពាវនាវអោយមានភាពងាយស្រួលបែបនេះ ក្នុងឱកាសបែបនេះផងដែរ។

សហគមន៍ទីបេរស់នៅនិរទេស មានបំណងផ្តល់នូវការគាំទ្រ និងជំនួយគ្រប់យ៉ាងដល់កិច្ចការជួយសង្គ្រោះ។ យើងខ្ញុំសង្ឃឹមថាវាអាចធ្វើបានតាមគ្រប់បណ្តាញដែលសមរម្យ និងត្រឹមត្រូវក្នុងពេលឆាប់ៗនេះ។

កាលពីរឆ្នាំមុន ស៊ីជូនទទួលរងនូវរញ្ជួយដី ហើយខ្ញុំក៏មានបំណងមកទស្សនកិច្ចតំបន់រងគ្រោះ ដើម្បីបួងសួង និងរំលែកទុក្ខប្រជាជននៅទីនោះ ប៉ុន្តែខ្ញុំមិនអាចធ្វើដូចនោះបាន។ យ៉ាងណាក៏ដោយ កាលឆ្នាំទៅ ខ្ញុំអាចធ្វើទស្សនកិច្ចទៅកាន់ក្រុមគ្រួសាររងគ្រោះខ្យល់ព្យុះទីវ៉ុង ក្នុងកោះតៃវ៉ាន់ និងបានឧទ្ទិសបួងសួងដល់វិញ្ញានក្ខន្ធទាំងឡាយណាដែលបានស្លាប់តែហោងក្នុងគ្រោះមហន្តរាយនោះ។ ខ្ញុំសប្បាយរីករាយនឹងធ្វើអ្វីៗដែលមានប្រយោជន៍ ក្នុងគោលបំណងសំរាលទុក្ខព្រួយរបស់ប្រជាជនដែលពាក់ព័ន្ធ។

ឥលូវនេះកន្លែងរញ្ជួយដីនៅ ឃ្យីចូដុ (ភាសាចិនៈ យូស៊ី) លាតសន្ធឹងក្នុងខេត្តជីងហាយ គឺបានកើតឡើងលើទឹកដីកំណើតរបស់ខ្ញុំទាំងពីរ គឺខ្ញុំ និង ព្រះតេជគុណចុងក្រោយ ប៉ាន់ជិន ឡាម៉ា។ ខ្ញុំមានបំណងធ្វើដំណើរដោយខ្លួនឯងទៅកាន់ទីនោះខ្លាំងណាស់ ដើម្បីសំរាលទុក្ខព្រួយ និងដើម្បីបំពេញបំណងរបស់ប្រជាជនជាច្រើននាក់ទាំងនោះ។

ជាសេចក្តីបញ្ចប់ ខ្ញុំសូមធ្វើការអំពាវនាវដល់រដ្ឋាភិបាលទាំងឡាយ បណ្តារអង្គការជំនួយអន្តរជាតិ និងភ្នាក់ងារសង្គ្រោះទាំងអស់ មេត្តាបន្តផ្តល់ជំនួយអ្វីក៏ដោយដែលអាចធ្វើទៅបាន ដល់ក្រុមគ្រួសារទទួលរងគ្រោះក្នុងសោនាដកម្មនេះ ដើម្បីអោយពួកគេអាចស្តារជីវភាពរស់នៅរបស់ពួកគេឡើងវិញ។ ក្នុងគ្រានេះដែរ ខ្ញុំក៏សូមអំពាវនាវដល់ជនរស់រានមានជីវិតពីមហន្តរាយនេះ មេត្តាចាត់ទុកអ្វីដែលបានកើតឡើងនេះជាការប្រព្រឹត្តិទៅនៃកម្ម និងសូមបំប្លែងនូវភាពមិនអនុគ្រោះនោះទៅជាចំនុចវិជ្ជមានវិញ ព្រមទាំងបដិបត្តិជានិច្ចនូវសេចក្តីសង្ឃឹម និងរំពឹងជួបដោយសេចក្តីក្លាហាននូវការត្រលប់ថញក្រោយ ពីព្រោះពួកគេតស៊ូក្នុងការស្តារនូវអ្វីដែលពួកគេបានបាត់បង់។ ជាថ្មីម្តងទៀតខ្ញុំសូមធ្វើការបួងសួងជូនជនទាំងឡាយដែលបានបាត់បង់ជីវិត ក៏ជូនជនដែលរស់រានមានជីវិតអោយបានជាសះស្បើយ។

ឌាឡាយ ឡាម៉ា

ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១០

http://www.tibet.net/index.php#